# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៧៥៨ MIH / ២០១៧

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍ធ្វើតេស្ត និងមន្ទីរពិសោធន៍ព្យាសកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៣៥ MIH / 2014 ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានវាយតម្លៃទទួលស្គាល់
- បានឃើញប្រកាសលេខ ៥២៣ MIH / 2014 ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់
- បានឃើញប្រកាសលេខ ១៦១ MIH / 2015 ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមុខងារ និងភារកិច្ចរបស់នាយកដ្ឋានវាយតម្លទទួលស្គាល់
- យោងតាមស្មារតីអង្គប្រជុំក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់លើកទី២ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍ធ្វើតេស្ត Technical Committee (TC) for Testing អនុលោមតាមស្តង់ដារអន្តរជាតិ ISO/IEC 17025 ដែលមានសមាសភាពដូចខាងក្រោម៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ២១១ ៨៥៤
អ៊ីម៉ែល: mih.smcabinet@gmail.com

| | | |
|---|---|---|
| ១- លោក យុន ស្រ៊ុន | អគ្គនាយកមន្ទីរពិសោធន៍សំណង់ និងសាធារណការ តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- លោកបណ្ឌិត ហ៊ុល សៀងហេង | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ តំណាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | អនុប្រធាន |
| ៣- លោក ហួយ វុត្ថា | ប្រធាននាយកដ្ឋាន តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៤- លោកស្រី ញ៉ឹម សុភា | អនុប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៥- លោក ជា អ៊ាកឃីម | អនុប្រធាននាយកដ្ឋានតំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦- លោកស្រី មាស ច័ន្ទធីតា | ប្រធានមន្ទីរពិសោធន៍តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៧- លោក ហុក សៀង | អនុប្រធានមន្ទីរពិសោធន៍ជាតិកសិកម្ម នៃ អគ្គនាយកដ្ឋានកសិកម្ម តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |

**ប្រការ២._**

ត្រូវបានបង្កើតគណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍ព្យាសកម្ម Technical Committee (TC) for Calibration អនុលោម តាមស្តង់ដារអន្តរជាតិ ISO/IEC 17025 ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោក គង់ បញ្ញាវិទ្ធ | ប្រធាននាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ នៃ មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ តំណាងក្រសួង ឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២- លោកបណ្ឌិត អោ ចាន់ម៉ូលី | សាស្ត្រាចារ្យ មជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ តំណាងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | អនុប្រធាន |
| ៣- លោក សែ ស៊ីម | ប្រធានការិយាល័យ តំណាងក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៤- លោក ម៉េង លាង | ប្រធានផ្នែកទំនាក់ទំនងអតិថិជន នៃមន្ទីរពិសោធន៍ សំណង់ និងសាធារណការ តំណាងក្រសួង សាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥- លោកស្រី ជួន មណីរង្សី | ប្រធានមន្ទីរពិសោធន៍កសិកម្មកម្ពុជា នៃនាយកដ្ឋាន កសិ-ឧស្សាហកម្ម តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦- លោក ជា វណ្ណារ៉ា | ប្រធានការិយាល័យវិភាគគុណភាពទឹក នៃ នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៧- លោក ស៊ីវ គង់ | អនុប្រធានមន្ទីរពិសោធន៍ តំណាងក្រសួងបរិស្ថាន | សមាជិក |

**ប្រការ៣._**

គណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍ធ្វើតេស្ត ឬមន្ទីរពិសោធន៍ព្យាសកម្ម មានភារកិច្ចដូចតទៅ៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

- រៀបចំបង្កើតលក្ខខណ្ឌបច្ចេកទេសជាក់លាក់តាមនីតិវិធី និងពិធីការ (Protocol) នៃមន្ទីរពិសោធន៍ធ្វើតេស្ត ឬមន្ទីរពិសោធន៍ព្យាសកម្ម ស្តីពីគុណភាព សមត្ថភាព និងសុវត្ថិភាព ដើម្បីជួយគាំទ្រដល់កិច្ចដំណើរការប្រព័ន្ធវាយតម្លៃទទួលស្គាល់ជាតិកម្ពុជា
- ផ្តល់យោបល់លើគោលការណ៍ ការងារវាយតម្លៃទទួលស្គាល់ នៃមន្ទីរពិសោធន៍ធ្វើតេស្ត ឬមន្ទីរពិសោធន៍ព្យាសកម្ម
- សហការ និងគាំទ្រដល់ផ្នែកជំនាញនៃនាយកដ្ឋានវាយតម្លៃទទួលស្គាល់ លើការងារវាយតម្លៃទទួលស្គាល់ដល់មន្ទីរពិសោធន៍ធ្វើតេស្ត ឬមន្ទីរពិសោធន៍ព្យាសកម្ម។

**ប្រការ៤._**

គណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍ធ្វើតេស្ត និងមន្ទីរពិសោធន៍ព្យាសកម្ម ត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់តាមការអញ្ជើញរបស់ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ ដែលជាសមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់។ កិច្ចប្រជុំអាចប្រព្រឹត្តទៅបានលុះត្រាតែមានកូរ៉ុមលើសពីពាក់កណ្តាលនៃសមាជិកសរុប។ រាល់សេចក្តីសម្រេចណាមួយនៃអង្គប្រជុំរបស់គណៈកម្មការបច្ចេកទេស ត្រូវយកតាមមតិភាគច្រើនដាច់ខាត នៃសមាជិកវត្តមានក្នុងកិច្ចប្រជុំ។ នៅពេលប្រធានអវត្តមាន កិច្ចប្រជុំអាចដំណើរការទៅបានក្រោមការដឹកនាំរបស់អនុប្រធាន។ ក្នុងករណីអវត្តមានប្រធាន និងអនុប្រធាន ការប្រជុំត្រូវដឹកនាំដោយសមាជិកតំណាងណាម្នាក់ដែលបានទទួលការប្រគល់សិទ្ធិពីសមាជិកមានវត្តមានក្នុងពេលប្រជុំ។

**ប្រការ៥._**

គណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍ធ្វើតេស្ត និងមន្ទីរពិសោធន៍ព្យាសកម្ម មាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ជាលេខាធិការដ្ឋានធ្វើការសម្របសម្រួលរាល់ការងារទាំងអស់ នៃគណៈកម្មការបច្ចេកទេសមន្ទីរពិសោធន៍ធ្វើតេស្ត ឬមន្ទីរពិសោធន៍ព្យាសកម្ម។

**ប្រការ៦._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានវាយតម្លៃទទួលស្គាល់ គ្រប់អង្គភាពពាក់ព័ន្ធ និងសមាសភាពគណៈកម្មការដូចមានចែងក្នុងប្រការ១ និងប្រការ២ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**និងជាប្រធានក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ *«ដើម្បីជូនជ្រាប»*
- ដូចប្រការ៧ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com